**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Aug-2014, 14:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរួមសុំការសម្រេចឡើងវិញស្តីពីការអនុវត្តវិធាន៨៧(៤) ក្នុងសំណុំរឿង០០២/០២ និងសេចក្តីសន្និដ្ឋានទាក់ទងនឹងភាពមិនអាចអនុវត្តបាននៃវិធាន៨៧(៤) ចំពោះសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“ភាគី”) សូមស្នើអង្គជំនុំជម្រះសាលាដំបូង៖ ក) អនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ដោយសុំពិចារណាឡើងវិញអំពីការអនុវត្តវិធាន៨៧(៤) ក្នុងបរិបទនៃសវនាការខាងមុខក្នុងសំណុំរឿង០០២/០២ និង ខ) សម្រេចថា សម្ភារៈទាំងអស់ដែលមានរួចជាស្រេចនៅក្នុងសំណុំរឿង គិតត្រឹមពេលសវនាការបឋម (រួមទាំងសម្ភារៈមិនមែនសំណុំរឿងដែលបានដាក់បញ្ចូលដោយភាគីណាមួយនៅលើបញ្ជីរបស់ខ្លួនស្របតាមវិធាន៨០) មិនមែនជា “សម្ភារៈថ្មី” តាមន័យដូចមានចែងក្នុងវិធាន៨៧(៤)ឡើយ។

២. សំណើសុំការសម្រេចឡើងវិញដែលបានធ្វើឡើងនេះ គឺដោយសារតែភាពចាំបាច់ធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនាពេលថ្មីៗនេះ លើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២/០២ ដែលសេចក្តីសម្រេចនេះបានបញ្ជាក់ថា ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ មាន “ផលវិបាកខាងផ្នែកនីតិវិធី” នៅក្នុងការបង្កើត “សវនាការផ្សេងគ្នា និងដាច់ដោយឡែកពីគ្នា”។ ការសម្រេចមួយអំពីថា តើសម្ភារៈនៅលើសំណុំរឿង គឺជា “ភ័ស្តុតាងថ្មី” នៅក្រោមវិធាន៨៧(៤) ដែរឬទេនោះ គឺចាំបាច់ដើម្បីឲ្យភាគីយល់ថា តើសម្ភារៈភ័ស្តុតាងដែលខ្លួនបានស្នើឡើងណាមួយក្នុងសំណុំរឿង ០០២/០២ នឹងត្រូវបានពិចារណាថា “ភ័ស្តុតាងថ្មី” ស្របតាមលក្ខខណ្ឌតម្រូវនៃការអនុវត្តវិធាន ៨៧(៤)។ និយាយដោយឡែក ភាគីស្នើសុំឲ្យមានការសម្រេចនេះឡើង គឺដើម្បីអនុវត្តទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យដាក់ញត្តិស្របតាមវិធាន៨៧(៤) សម្រាប់ឯកសារទាំងអស់ដែលជា “ភ័ស្តុតាងថ្មី”។

## II. ប្រវត្តិនីតិវិធី

៣. ភាគីសូមធ្វើការបង្រួមប្រវត្តិនីតិវិធី តាមរយៈការយោងទៅរកសំណើដែលបានដាក់កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ដែលនោះជាសំណើសុំឲ្យសម្រេចស្តីពីការអនុវត្តវិធាន៨៧(៤) ក្នុងសំណុំរឿង ០០២/០២ (“សំណើតាមវិធាន៨៧(៤)”)[1]។ ក្នុងសំណើតាមវិធាន៨៧(៤)នេះ ភាគីបានសន្និដ្ឋាន

[1] **E307** សំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) នៅក្នុងសំណុំរឿង០០២/០២, ៣០ មេសា ២០១៤, កថាខណ្ឌ៤-៥។

ថា សំណុំរឿង០០២/០១ និង០០២/០២ បង្កើតឱ្យមានសវនាការដាច់ដោយឡែកពីគ្នា។ ភាគីតវ៉ាថា ស្របតាមវិធាន៨០*ស្ទួន*(១) សវនាការមួយត្រូវតែមានសវនាការបឋម និងថានៅក្នុងសវនាការនិមួយៗ ការអនុវត្តវិធាន៨៧(៤) បានចំពោះតែភ័ស្តុតាងណាដែលបានស្នើឱ្យទទួលយកនៅក្រោយសវនាការបឋមដែលពាក់ព័ន្ធប៉ុណ្ណោះ[2]។ ភាគីយល់ឃើញថាការបកស្រាយដូច្នេះគឺស៊ីសង្វាក់គ្នាជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវរបស់ជនជាប់ចោទ ហើយនឹងជួយសម្រួលដល់ការស្វែងរកការពិត។ ភាគីក៏បានស្នើសុំផងដែរថា ការដាក់លក្ខខណ្ឌតម្រូវឱ្យភាគីដាក់សំណើសុំជាច្រើនស្របតាមវិធាន៨៧(៤) ទាក់ទងនឹងសាក្សី និងឯកសារដែលមិនបានបញ្ចូលក្នុងបញ្ជីឆ្នាំ២០១១រៀងៗខ្លួន គឺគ្មានប្រយោជន៍អ្វីដល់ភាគីណាមួយទេ ហើយក៏នឹងធ្វើឱ្យមានការពន្យារពេលច្រើនហួសហេតុចំពោះកិច្ចដំណើរការនីតិវិធីផងដែរ[3]។

៤. អង្គជំនុំជម្រះសាលាដំបូង បានធ្វើការឆ្លើយតបទៅនឹងសំណើស្របតាមវិធាន៨៧(៤)នេះ តាមរយៈអនុស្សរណៈមួយ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤។ អង្គជំនុំជម្រះមិនទទួលការបកស្រាយនេះទេ ផ្ទុយទៅវិញ បានសម្រេចថា៖ ក) "សវនាការសំណុំរឿង០០២" បានចាប់ផ្តើម ចាប់ពីសវនាការបឋមថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១១ មក; ខ) កិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ ត្រូវបានបំបែកជាបន្តបន្ទាប់ទៅជា"សំណុំរឿងដាច់ដោយឡែកពីគ្នា"; គ) "សវនាការវគ្គដំបូង" មានបំណងធ្វើជាមូលដ្ឋានគ្រឹះ សម្រាប់ការដេញដោលបន្ថែមទៀតលើបទចោទដែលនៅសល់ "នៅក្នុងសវនាការក្រោយៗ"; ឃ) កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ <u>យ៉ាងណាមិញ ត្រូវបានគេមើលឃើញថាជាផ្នែកនៃ"សំណុំរឿងទាំងមូល"</u> ដែលបញ្ហាចំបងត្រូវបានដោះស្រាយនៅពេលបើក "សវនាការ" ក្នុងសំណុំរឿង០០២ ក្នុងខែមិថុនា ឆ្នាំ២០១១ និង ង) "សវនាការ" ក្នុងសំណុំរឿង០០២ បានចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ២០១១ និងបញ្ហានីតិវិធីដែលបានដោះស្រាយក្នុងពេលនោះគឺពាក់ព័ន្ធនឹង "សវនាការជាបន្តបន្ទាប់ក្រោយៗ" ទាំងអស់[4]។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះនៅតែប្រកាន់ជំហរថា កន្លងមក ខ្លួនអាចនឹងទទួលយកភ័ស្តុតាងថ្មីបើទោះជាភ័ស្តុតាងនោះ មិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវ នៃវិធាន៨៧(៤) ក៏ដោយ[5]។ អង្គជំនុំជម្រះបានអញ្ជើញឱ្យភាគីដាក់

---

[2] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ៧-៨។

[3] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ៩-១១។

[4] **E307/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/4), ១១ មិថុនា ២០១៤, ត្រង់កថាខណ្ឌ២។

[5] ដដែលដូចខាងលើ, កថាខណ្ឌ៣។

ពាក្យសុំស្របតាមវិធាន៨៧(៤) ទាក់ទងនឹងបុគ្គលដែលមិនបានបញ្ចូលក្នុងបញ្ជីដំបូងឆ្នាំ២០១១ របស់ខ្លួន[6]។

៥. នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ មេធាវីការពារក្តី នួន ជា បានដាក់បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មីរបស់ខ្លួន សម្រាប់សំណុំរឿង០០២/០២[7]។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់សំណើតាមវិធាន៨៧(៤)របស់ខ្លួនទាក់ទងនឹងសាក្សីសវនាការថ្មីដែលបានស្នើឡើង[8]។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើតាមវិធាន៨៧(៤)របស់ខ្លួន ទាក់ទងនឹងសក្ខីកម្មផ្ទាល់មាត់ ឯកសារ និងវត្ថុតាងទាក់ទងនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើងឲ្យមកបំភ្លឺក្នុងសំណុំរឿង០០២/០២[9]។ សវនាការបឋមបន្ថែមក្នុងសំណុំរឿង០០២/០២ ត្រូវបានធ្វើឡើងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤[10]។

៦. នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២[11] (សេចក្តីសម្រេចរបស់អង្គជំនុំជម្រតុលាការកំពូល")។

## III. សំណើសុំពិចារណាឡើងវិញលើសេចក្តីសម្រេចអំពីការអនុវត្តវិធាន៨៧(៤)

### *iii. ក. មូលដ្ឋានផ្លូវច្បាប់សម្រាប់សំណើ*

[6] ដដែលដូចខាងលើ, កថាខណ្ឌ៥។

[7] **E307/4** បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មីសម្រាប់សំណុំរឿង០០២/០២, ២៤ កក្កដា ២០១៤។

[8] **E307/3/2** សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសាក្សីដែលបានស្នើសុំសម្រាប់សវនាការ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងសម្រាប់សំណុំរឿង០០២/០២, ២៨ កក្កដា ២០១៤។

[9] **E307/6** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យទទួលយកភ័ស្តុតាងសក្ខីកម្មផ្ទាល់មាត់ និងឯកសារ និងវត្ថុតាង អនុលោមតាមវិធាន៨៧(៤) ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីស្នើមកបំភ្លឺក្នុងសំណុំរឿង០០២/០២, ២៩ កក្កដា ២០១៤។

[10] **E1/240.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី - សវនាការបឋម, ៣០ កក្កដា ២០១៤។

[11] **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ២៩ កក្កដា ២០១៤។

៧. អង្គបុរេជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនៃ អ.វ.ត.ក មានអំណាចឆន្ទានុសិទ្ធិជាប់មកតាមខ្លួន ដើម្បីពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនៗរបស់ខ្លួន ប្រសិនបើមាន "មូលដ្ឋានផ្លូវច្បាប់" ក្នុងការអនុវត្តដូច្នេះ[12]រួមទាំងនៅពេលណាមានការផ្លាស់ប្តូរកាលៈទេសៈ[13] និង "ប្រសិនបើខ្លួនយល់ថា សេចក្តីពីមុននោះមានការភាន់ច្រឡំ ឬបណ្តាលឱ្យមានភាពអយុត្តិធម៌ណាមួយ"[14]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាឡើងវិញលើសេចក្តីសម្រេច ស្តីពីការគ្រប់គ្រងសំណុំរឿងរបស់ខ្លួន "ដរាបណាការពិចារណាឡើងវិញនេះ មិនប្រឆាំងនឹងផលប្រយោជន៍នៃយុត្តិធម៌"[15]។

៨. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដោយសារតែវិធានផ្ទៃក្នុងមិនបានចែងអំពីការពិនិត្យឡើងវិញលើសេចក្តីសម្រេចនោះ ខ្លួនពុំមានបំណងនឹងធ្វើការពិចារណាលើសំណើនេះនោះឡើយ[16]។ ថ្វីដ្បិតតែអង្គជំនុំជម្រះនេះបានទទួលស្គាល់ថា ការកើតឡើងនូវអង្គហេតុ ឬកាលៈទេសៈថ្មីៗនៅក្រោយពេលចេញសេចក្តីសម្រេច អាចអនុញ្ញាតឱ្យពិនិត្យ*សាជាថ្មីឡើងវិញ* អំពីបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេច[17]។ ភាគីនានាសន្និដ្ឋានថា សម្រេចរបស់តុលាការកំពូល

[12] **C22/I/68** សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ២៨ សីហា ២០០៨, ត្រង់កថាខណ្ឌ២៥។

[13] **D99/3/41** សេចក្តីសម្រេចលើពាក្យសុំរបស់ អៀង សារី សុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង "ឌុច", ៣ ធ្នូ ២០០៨, ត្រង់កថាខណ្ឌ៦។

[14] **C22/I/68** សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ២៨ សីហា ២០០៨, ត្រង់កថាខណ្ឌ២៥, លើកយោងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galic,* សំណុំរឿងលេខ: IT-98-29-AR73, សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការ សុំការអនុញ្ញាតប្តឹងឧទ្ធរណ៍, ១៤ ធ្នូ ២០០១, កថាខណ្ឌ១៣ និងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucic និងគូកន.,* សំណុំរឿងលេខ: IT-96-21-*Abis*, សាលដីកាលើបណ្តឹងសាទុក្ខអំពីការកាត់ទោស, ៨ មេសា ២០០៣, កថាខណ្ឌ៤៩។

[15] **E284/2/1/2** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ, ២៦ មិថុនា ២០១៣, ត្រង់កថាខណ្ឌ៨ (ពាក់ព័ន្ធនឹងបញ្ហានៃការបើកកិច្ចដំណើរការនីតិវិធីឡើងវិញ)។

[16] ឯកសារលេខ **E312** សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿងលេ០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ , ត្រង់កថាខណ្ឌទី៣៩។

[17] ឯកសារលេខ **E313** សាលក្រម, សំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៧ សីហា ២០១៤, ត្រង់កថាខណ្ឌទី៤២ , ["ជនជាប់ចោទមិនបានលើកអង្គហេតុ ឬកាលៈទេសៈថ្មី ចាប់តាំងពីចេញសេចក្តីសម្រេចទាំងនេះ ហេតុដូចនេះ សំណើ*តាមការដាក់ស្តែង* របស់គាត់ដែលបានស្នើសុំឱ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗទាំងអស់នោះ សុទ្ធតែមិនអាចទទួលយកបាន។"]។ សូមមេត្តាអានផងដែរនូវកថាខណ្ឌទី៤៣ និង៤៤, និងលេខយោងជើងទំព័រលេខ ២១៥៤ ["អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីរបស់ អៀង សារី លើកទឡ្ហីករណ៍មុនៗដែលរបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និង ទី២ មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេត្រឹមឆ្នាំ១៩៧៥ ហើយពុំបានបង្ហាញអង្គហេតុថ្មី ឬកាលៈទេសៈថ្មីណាមួយ

គឺតំណាងឲ្យកាលៈទេសៈថ្មីមួយដែលបានលេចឡើងចាប់តាំងពីពេលចេញសេចក្តីសម្រេច ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូងមកម្ល៉េះ ពីព្រោះសេចក្តីសម្រេចនេះបានបំភ្លឺ និងពង្រីកបន្ថែមនូវគោលការណ៍នានាដែលមានវិសាលភាព ចំពោះការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ។

## *III.ខ. អំពីផលប៉ះពាល់នៃសេចក្តីសម្រេចរបស់តុលាការកំពូល ទៅលើវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង*

៩. ដូចដែលបានលើកឡើងនៅក្នុងផ្នែកទីII ខាងលើ នៅក្នុងអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ទោះបីជាការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២ បានមានឥទ្ធិពលក្នុងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងឲ្យដាច់ៗពីគ្នានោះក៏ដោយ ក៏សំណុំរឿងទាំងនេះគឺជាផ្នែកនៃ“<u>ការជំនុំជម្រះក្តីទាំងមូល” ឬ“សំណុំរឿងទាំងមូល</u>”ដែរ ហើយដំណាក់កាលផ្សេងៗនៃនីតិវិធី (ដូចជាការដាក់ជូននូវបញ្ជីឈ្មោះសាក្សី ឬបញ្ជីឯកសារនានា) ដែលបានយកនៅមុនពេលធ្វើសវនាការបឋម នាខែមិថុនា ឆ្នាំ២០១១ ក្នុងសំណុំរឿងលេខ០០២ ត្រូវយកមកអនុវត្តនៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ជាបន្តបន្ទាប់មកទៀត។ ជាផលវិបាកនៃការសម្រេចនោះ នៅក្នុងសំណុំរឿងលេខ០០២/០២ វិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ត្រូវបានយកមកអនុវត្តចំពោះរាល់សាក្សី និងឯកសារទាំងអស់ ដែលភាគីនានាបានស្នើឡើងបន្ទាប់ពីពេលធ្វើសវនាការបឋម។

១០. ភាគីនានាសន្និដ្ឋានថា អង្គជំនុំជម្រះត្រូវតែពិចារណាលើបញ្ហានេះ*សាជាថ្មីឡើងវិញ* តាមស្មារតីនៃសេចក្តីសម្រេចរបស់តុលាការកំពូល។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកត់សម្គាល់ថា

---

ដែលលេចចេញចាប់តាងពីពេលដែលសេចក្តីសម្រេចនានា ត្រូវបានធ្វើឡើងដោយផ្អែកលើសេចក្តីសន្និដ្ឋានមុនៗទាំងនេះ... អាស្រ័យហេតុនេះ សំណើសុំឲ្យធ្វើការពិចារណាសាជាថ្មីនេះ មិនអាចទទួលយកបានឡើយ។”]។ ឯកសារលេខ **E312** សេចក្តីសម្រេចស្តាពរស្តីពីសាក្សីអ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿងលេ០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ , ត្រង់កថាខណ្ឌទី៣៨ [ដែលថ្លែងថា, ទាក់ទងនឹងសំណើសុំឲ្យពិចារណាឡើងវិញ ស្តីពីភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សរ សារិន (Sar Sarin)នោះ “អង្គជំនុំជម្រះបានសម្រេចបដិសេធលើសំណើរបស់ កសព ដោយយល់ឃើញថា <u>ទោះបីជាសំណើសុំនេះត្រូវបានចាត់ទុកថាជាសំណើសុំថ្មីក៏ដោយ</u> <u>ក៏ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានលើកឡើងពីកាលៈទេសៈថ្មីៗនោះទេ</u>”។ (ការសង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម)]។ សូមមេត្តាអានផងដែរនូវឯកសារលេខ **E127/4** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិនិត្យឡើងវិញលើលក្ខខណ្ឌនៃដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំនើរការនីតិវិធី (ឯកសារលេខ E124/2) និងញត្តិព្រមទាំងឧបសម្ព័ន្ធនានាដែលពាក់ព័ន្ធ, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១, ត្រង់កថាខណ្ឌទី២ និងសេចក្តីសម្រេចបញ្ចប់ [អង្គជំនុំជម្រះបដិសេធលើសំណើសុំឲ្យពិចារណាជាថ្មីលើអង្គសេចក្តី ហើយតែមិនមែនដោយផ្អែកលើមូលដ្ឋានថា មិនអាចទទួលយកបានឡើយ]។

ចាំបាច់ត្រូវតែមានការបញ្ជាក់បំភ្លឺមួយអំពីលក្ខណៈនៃការបំបែកកិច្ចដំណើរការនីតិវិធី[18] និងផ្តល់ការណែនាំមានសារៈសំខាន់ដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចយ៉ាងច្បាស់លាស់ថា ការបំបែកកិច្ចដំណើរការនីតិវិធី បានបង្កើតជាសំណុំរឿងដាច់ពីគ្នា និងផ្សេងពីគ្នា និងថា បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីមក សំណុំរឿងនីមួយៗ ត្រូវដាក់ឲ្យស្ថិតនៅក្រោមនីតិវិធីដាច់ដោយឡែកពីគ្នា។ ការសម្រេចនេះ មិនស្របតាមតក្កភាពនៃការសម្រេចកាលពីលើកមុនរបស់អង្គជំនុំជម្រះ ស្តីពីសំណើសុំរួមរបស់ភាគីនានាអនុលោមតាមវិធាន៨៧(៤)ដែលបានលើកឡើងពីដំបូង ស្តីពីការពិចារណាសំណុំរឿងលេខ០០២/០២ ថាជាផ្នែកនៅក្នុងការជំនុំជម្រះក្តីតែមួយជាមួយគ្នានឹងសំណុំរឿងលេខ០០២/០១ ដែលបានចាប់ផ្តើមដោយសវនាការបឋមនៅក្នុងឆ្នាំ២០១១។ ជាការជាក់លាក់ គឺអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា៖

ក. អនុលោមតាមវិធាន៨៩*ស្ទួនពីរ* ដែលគ្រប់គ្រងលើដំណើរការនីតិវិធីនៃការបំបែកកិច្ចដំណើរការនីតិវិធី "ការបំបែកកិច្ចដំណើរការនីតិវិធី គឺចង្អុលបង្ហាញពីការបំបែកឲ្យដាច់ពីគ្នា (ឬកាត់ផ្តាច់ចេញពីគ្នា) នៃកិច្ចដំណើរការនីតិវិធី ដែលផលវិបាកនោះ គឺជំនួសឲ្យសំណុំរឿងព្រហ្មទណ្ឌមួយ គឺមានសំណុំរឿងព្រហ្មទណ្ឌដល់ទៅពីរ ឬលើសពីពីរ"។[19]

ខ. ការបំបែកកិច្ចដំណើរការនីតិវិធីកំណត់អំពីវិសាលភាពនៃសំណុំរឿងនីមួយៗ ដែលបានបំបែកកិច្ចដំណើរការនីតិវិធីរួច[20]។

គ. ការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអានុភាពដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីបានបង្កើតឡើងនូវការជំនុំជម្រះក្តីដែលដាច់ពីគ្នា និងផ្សេងគ្នា ដែល "ស្របទៅតាមលក្ខណៈនៃការបំបែកកិច្ចដំណើរការនីតិវិធី.... ដែលផលវិបាកលើដំណើរការនីតិវិធីនោះ គឺការបង្កើតការជំនុំជម្រះក្តីដែលដាច់ពីគ្នា និងផ្សេងគ្នា"[21]។

---

[18] ឯកសារលេខ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៃសំណុំរឿងលេខ០០២ និងវិសាលភាពនៃសំណុំរឿងលេខ០០២/០២ , ចុះថ្ងៃទី២៩ កក្កដា ២០១៤, ត្រង់កថាខណ្ឌទី៤១។

[19] *ដូចគ្នានឹងខាងលើ,* ត្រង់កថាខណ្ឌទី៤២ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[20] *ដូចគ្នានឹងខាងលើ,* ត្រង់កថាខណ្ឌទី៤៤។

[21] *ដូចគ្នានឹងខាងលើ,* ត្រង់កថាខណ្ឌទី៧០ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

ឃ. ប្រការដែលថា ភស្តុតាងមានភាពរួមតែមួយជាមួយគ្នា ក្នុងករណីសំណុំរឿងមួយត្រូវបានបំបែកកិច្ចដំណើរការនីតិវិធី បន្ទាប់ពីការចាប់ផ្តើមការជំនុំជម្រះនោះ មិនធ្វើឲ្យមានការប្រែប្រួលដល់អានុភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីទេ (*គឺថា*ការបង្កើតជាសំណុំរឿងដាច់ពីគ្នា/ការជំនុំជម្រះក្តីចាប់តាំងពីចំណុចនោះទៅ)[22]។

ង. ផលវិបាកមួយនៃការបំបែកកិច្ចដំណើរការនីតិវិធីគឺថា"<u>បញ្ហានានាស្តីពីសិទ្ធិដែលលេចចេញពីរយៈពេលនៃដំណើរការនីតិវិធី និងការឃុំខ្លួនមុនពេលសវនាការជាបន្ទាប់មកទៀត ត្រូវបានធ្វើការវាយតម្លៃដាច់ដោយឡែកពីគ្នាសម្រាប់សំណុំរឿងព្រហ្មទណ្ឌនីមួយៗ</u> ដែលបានបង្កើតឡើងតាមបែបដូច្នេះ"[23]។

១១. នៅក្នុងពេលដែលកំពុងធ្វើការកត់សម្គាល់ទៅលើភាពខុសគ្នានៃភាសា ដែលបានអមទៅជាមួយនឹងការប្រកាសផ្សេងៗស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលមានភាពច្បាស់លាស់នៅក្នុងការកំណត់សម្រេចរបស់ខ្លួនថា ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងតាមវិធាន៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ជាលទ្ធផលគឺបណ្តាលឲ្យមានការបង្កើតឡើងនូវសំណុំរឿងដែលដាច់ពីគ្នា និងផ្សេងគ្នា[24]។

១២. ដូចដែលបានធ្វើការកត់សម្គាល់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការបង្កើតឡើងនូវសំណុំរឿងដែលដាច់ពីគ្នា គឺតម្រូវឲ្យមានការសម្រេចដាច់ដោយឡែកពីគ្នាស្តីពីសិទ្ធិផ្សេងៗដែលទាក់ទងនឹងនីតិវិធីរបស់ភាគីនានានៅក្នុងសំណុំរឿងនីមួយៗ។ ភាគីទាំងអស់ជូនជាយោបល់ថា នេះគឺបានន័យថា យន្តការទាក់ទងនឹងនីតិវិធីនៅក្នុងវិធាន៨០ និងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងត្រូវយកមកអនុវត្តដាច់ដោយឡែកពីគ្នា នៅក្នុងការជំនុំជម្រះក្តីនីមួយៗ។ ការជំនុំជម្រះក្តីនីមួយៗដោយមានសវនាការបឋមដែលដោះស្រាយពាក់ព័ន្ធនឹងសាក្សី និងឯកសារនានាដែលនឹងត្រូវលើកយកមកពិចារណានៅក្នុងពេលជំនុំជម្រះក្តី។ សវនាការបឋមជាបន្តមកទៀត នៅថ្ងៃទី២៩ ខែកក្កដា

[22] *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី៤៣ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។ សូមមេត្តាអានផងដែរនូវកថាខណ្ឌទី៧៦។

[23] *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី៤៤ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[24] *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី៧២។ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការកត់សម្គាល់ផងដែរថា សំណុំរឿងដាច់ពីគ្នាដែលបានបង្កើតឡើងដោយសារការបំបែកកិច្ចដំណើរការនីតិវិធី អាចនឹងត្រូវបានធ្វើការជំនុំជម្រះដោយអង្គចៅក្រមជំនុំជម្រះផ្សេងគ្នា (ត្រង់កថាខណ្ឌទី៤៥)។

ឆ្នាំ២០១៤ គឺជាសវនាការលើកដំបូង ដើម្បីពិចារណាលើសាក្សី និងឯកសារនានាដែលទាក់ទងទៅនឹងការចោទប្រកាន់ដែលត្រូវស្ដាប់ចម្លើយនៅក្នុងសំណុំរឿងលេខ០០២/០២។

១៣. នៅក្នុងសវនាការនីមួយៗ អង្គជំនុំជម្រះអាចចេញដីកាបង្គាប់ឱ្យភាគីនានាដាក់បញ្ជីឈ្មោះសាក្សី និងភស្តុតាងជាឯកសារនានាដែលបានស្នើឡើង (ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើនៅក្នុងសំណុំរឿងលេខ០០២/០១[25] និងសំណុំរឿងលេខ០០២/០២[26])។ នៅក្នុងសវនាការជំនុំជម្រះក្ដីនីមួយៗ វិធាន៨៧(៤) បានតម្រូវឱ្យមានការចាប់ផ្ដើមដោយលក្ខខណ្ឌតម្រូវខ្ពស់ជាងមុនសម្រាប់ការទទួលយកភស្តុតាងទាំងឡាយណាដែលមិនទាន់បានលើកស្នើ មុនពេលបើក(សវនាការបឋម) <u>នៃការជំនុំជម្រះនោះ</u>។ ប្រការដែលថា ករណីបើសិនជាមានភាពរួមតែមួយជាមួយគ្នានៃភាគីនានានោះ ភស្តុតាងទាំងឡាយដែលបានទទួលយកនៅក្នុងសំណុំរឿងមួយ អាចឱ្យធ្វើការផ្ទេរទៅកាន់សំណុំរឿងមួយទៀតបាន ដោយមិនធ្វើឱ្យមានការប្រែប្រួលដល់អានុភាពច្បាប់នៃបទប្បញ្ញត្តិទាំងនេះឡើយ។

១៤. ភាគីនានាក៏ជូនជាយោបល់ផងដែរថា បើសិនមិនមានការប្រែប្រួលនោះ ការបកស្រាយបច្ចុប្បន្ននៃវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង អាចបណ្ដាលឱ្យមានភាពមិនប្រាកដប្រជា និងអូសបន្លាយពេលដែលផ្ទុយទៅនឹងគោលការណ៍ជាសារវ័ន្តទាំងឡាយ ដែលមានចែងនៅក្នុងវិធាន២១(១) និងវិធាន២១(៤) នៃវិធានផ្ទៃក្នុង។ លើសពីនេះ បើសិនជាភស្តុតាងដែលពាក់ព័ន្ធ ត្រូវបានដកចេញ "ដែលអាចជាកត្តាដែលមានលក្ខណៈដាច់ខាត"នៅពេលជំនុំជម្រះ នោះវិធាន១០៨(៧)បានបង្ខំឱ្យអង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើការពិចារណាលើសំណើសុំឱ្យទទួលយកភស្តុតាងនោះនៅពេលបណ្ដឹងឧទ្ធរណ៍។ ហេតុដូចនេះ ការអនុម័តយកនូវការបកស្រាយមួយដែលមានលក្ខណៈចង្អៀតរបស់វិធាន៨៧(៤) អាចគ្រាន់តែធ្វើឱ្យអូសបន្លាយពេល និងធ្វើឱ្យមានភាពស្មុគ្រស្មាញចំពោះដំណើរការនីតិវិធីតែប៉ុណ្ណោះ និងបង្កើននូវលទ្ធភាពនៃការរកឃើញទាំងឡាយ នៅក្នុងសាលក្រមត្រូវបានច្រានចោល។

១៥. ភាគីនានាជូនជាមតិថា សេចក្ដីសម្រេចរបស់តុលាការកំពូល គឺជាកាលៈទេសៈមួយថ្មីដែលកំពុងតែកើតមានឡើងចាប់តាំងពីពេលចេញសេចក្ដីសម្រេចចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤មក ដែល

---

[25] ឯកសារលេខ **E9** ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

[26] ឯកសារលេខ **E305** ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿងលេខ០០២/០២, ចុះថ្ងៃទី៨ មេសា ២០១៤។

តម្រូវឲ្យធ្វើការសម្រេច*ឡើងវិញជាថ្មីម្ដងទៀត* លើការអនុវត្តវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង នៅក្នុងសំណុំរឿងលេខ០០២/០២។ ការបកស្រាយដែលសមហេតុសមផលតែមួយប៉ុណ្ណោះនៃវិធានផ្ទៃក្នុង តាមស្មារតីនៃសេចក្ដីសម្រេចរបស់តុលាការកំពូលនោះ គឺថា វិធាន៨៧(៤)ត្រូវយកមកអនុវត្តដាច់ដោយឡែកពីគ្នាទាក់ទងទៅនឹងការជំនុំជម្រះក្ដីនីមួយៗ។ ភាគីនានាសូមឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាធ្វើការសម្រេចយ៉ាងដូច្នេះ។

## IV. សំណើសុំឲ្យមានសេចក្ដីសម្រេចថា វិធាន ៨៧(៤) អនុវត្តចំពោះ ភស្តុតាងដែលមិនមាននៅក្នុងសំណុំរឿងតែប៉ុណ្ណោះ

១៦. ភាគីនានាកត់សម្គាល់លើសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះដែលថា គេត្រូវប្រញាប់ធ្វើសំណើរនានាដែលទាក់ទងនឹងវិធាន៨៧(៤) ឲ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន[27]។ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកទី **II** មានញត្តិមួយចំនួនត្រូវបានធ្វើរួចហើយ ដែលទាក់ទងនឹងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំនាពេលថ្មីៗនេះ។ ញត្តិសេសសល់ដែលត្រូវដាក់ គឺទាក់ទងជាសំខាន់ទៅនឹងឯកសារផ្សេងៗ។ ការសម្រេចរបស់អង្គជំនុំជម្រះលើសំណើភ្លាមមួយនេះ នឹងមានផលប៉ះពាល់ជាសំខាន់ទៅលើវិសាលភាព (ហើយបើដូច្នេះ គឺចំនួន) ឯកសារដែលទាក់ទងនឹងរឿងនេះ គឺគេត្រូវតែធ្វើញត្តិនានាស្ដីពីវិធាន៨៧(៤)។ ដូច្នេះ សំណើនេះត្រូវបានធ្វើឡើងបន្ថែមទៀត ហើយដែលផ្សេងគ្នានៃសំណើនៅក្នុងផ្នែកទី **III** ខាងលើ។

១៧. ភាគីនានាយល់ឃើញថា ការយោងនៃវិធាន៨៧(៤) អំពី "ភស្តុតាងថ្មី" គឺអនុវត្តបានចំពោះភស្តុតាងដែលលេចចេញមក ក្រោយពេលចាប់ផ្ដើមសវនាការតែប៉ុណ្ណោះ គឺថាត្រូវអនុវត្តចំពោះឯកសារទាំងឡាយណាដែលៈ ក) ពុំមាននៅក្នុងសំណុំរឿងនៅពេលសវនាការបឋមដែលពាក់ព័ន្ធ, និង ខ) បើមិនដូច្នោះទេ គឺពុំមានបញ្ចូលនៅក្នុងបញ្ជីស្របតាមវិធាន៨០ របស់ភាគីណាមួយ។ កាលណាគេអនុវត្តចំពោះសាក្សី និងអ្នកជំនាញ វិធាន៨៧(៤) គឺត្រូវអនុវត្តចំពោះបុគ្គលទាំងឡាយណាដែលៈ ក) ពុំមានកំណត់ហេតុស្ដាប់ចម្លើយដាក់រួចស្រេចនៅក្នុងសំណុំរឿងនៅពេលសវនាការបឋមដែលពាក់ព័ន្ធ, និង ខ) បើមិនដូច្នោះទេ គឺពុំមានបញ្ចូលដោយភាគីណាមួយ នៅក្នុងបញ្ជីឈ្មោះបុគ្គលដែលបានស្នើ ស្របតាមវិធាន៨០ ឲ្យមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការ។ ការ

[27] **E1/240.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី - សវនាការបឋម, ៣០ កក្កដា ២០១៤, ត្រង់ 11.22.54។

បកស្រាយនេះ លើកទឹកចិត្តដល់ភាគីនានា ក្នុងការធានាបានថា អង្គជំនុំជម្រះ និងភាគីដទៃទៀត មានការជូនដំណឹងអំពីភស្តុតាងដែលគេអាចនឹងប្រើប្រាស់នៅពេលសវនាការ នៅពេលណាដែលគេមានលទ្ធភាពអាចផ្តល់ការជូនដំណឹងបែបដូច្នោះបាន។

១៨. ការបកស្រាយនេះ ធ្វើឡើងទៅតាមការអានភាសាត្រង់ៗនៃវិធាន៨៧ ទាំងស្រុង។ ជាពិសេស គឺ៖

ក. វិធាន៨៧(១) ចែងថា លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ វិធាន៨៧(៣) និយាយអំពីការទទួលយក“ភស្តុតាងដែលមាននៅក្នុងសំណុំរឿង” ខណៈដែលវិធាន៨៧(៤) ចែងអំពីវិធានបន្ថែមសម្រាប់ “ភស្តុតាងថ្មី” ដែលគេបានស្នើឲ្យទទួលយក “ក្នុងកំឡុងពេលសវនាការ”។ ការយោងទៅដល់ “ភស្តុតាងថ្មី” នៅក្នុងវិធាន៨៧(៤) គឺច្បាស់ណាស់ ជាការយោងទៅដល់ឯកសារបន្ថែមទៅនឹងឯកសារដែលបានយោងនៅក្នុងវិធាន៨៧(៣) - គឺឯកសារដែលមិនមាននៅក្នុងសំណុំរឿងនៅពេលការចាប់ផ្តើមជំនុំជម្រះ។

ខ. ការអនុវត្តវិធាន៨៧(៤) ចំពោះភស្តុតាងដែលមាននៅក្នុងសំណុំរឿងនៅពេលការចាប់ផ្តើមជំនុំជម្រះ នឹងនាំមកនូវលទ្ធផលមួយដែលមិនទំនង៖ ភាគីដែលស្នើសុំ នឹងមិនមានលទ្ធភាពអាចបង្ហាញបានទាល់តែសោះ ថាភស្តុតាងបែបដូច្នោះ “ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ”[28]។ ការបកស្រាយបែបដូច្នោះ មិនអាចមានចេតនាពីសំណាក់អ្នកធ្វើពង្រាងបានទេ ជាពិសេស នៅពេលដែលភាសានៃវិធាន៨០ ត្រូវបានគេពិចារណា (សូមអានកថាខណ្ឌ (គ) នៅខាងក្រោមជាប់គ្នានេះ)។ លើសពីនេះ ការបកស្រាយបែបដូច្នោះ មុខជាលើកទឹកចិត្តដល់ភាគីនានា ឲ្យគ្រាន់តែចុះបញ្ជីនូវរាល់ភស្តុតាង និងសាក្សីទាំងអស់ ដែលមាននៅក្នុងសំណុំរឿង នៅក្នុងបញ្ជីរបស់ពួកគាត់ ស្របតាមវិធាន៨០ ដោយគ្រាន់តែរក្សាសិទ្ធិក្នុងការដាក់ជូននូវភស្តុតាងបែបដូច្នោះ។

គ. វិធាន៨០ ស្នើដោយប្រយោលថា បញ្ជីឈ្មោះសាក្សី និងឯកសារ នៅមុនពេលសវនាការរបស់ភាគីនានា ពុំមែនផ្តាច់ព្រ័តទេ។ នេះមានលក្ខណៈច្បាស់លាស់នៅក្នុងពាក្យពេចន៍នៃអនុវិធាន៨០(១), ៨០(៣)(ខ) និង៨០(៣)(ឃ)។ នៅក្នុងបទប្បញ្ញត្តិទាំងនេះ អង្គជំនុំ

[28] ឯកសារដែលមាននៅក្នុងសំណុំរឿងនៅពេលបើកការជំនុំជម្រះ តាមនិយមន័យ គឺទាំងអង្គជំនុំជម្រះ និងទាំងភាគីនានា “អាចរកបាន”។

ជម្រះអាចបង្គាប់ឲ្យភាគីនានាដាក់បញ្ជីភស្តុតាង ដែលគេ "មានបំណង" ប្រើប្រាស់នៅពេលសវនាការ។ បញ្ជីទាំងនេះផ្តល់នូវការជូនដំណឹងយ៉ាងសមហេតុសមផលអំពីភស្តុតាងដែលភាគីនីមួយៗអាចនឹងពឹងផ្អែកលើ និងជួយសម្រួលដល់ការត្រៀមរៀបចំសវនាការយ៉ាងមានប្រសិទ្ធភាព។ យ៉ាងណាក៏ដោយ វិធានទាំងនេះគឺច្បាស់ណាស់ មិនចាត់ទុកបញ្ជីទាំងនេះថាមានលក្ខណៈប្រាកដប្រជានោះទេ គឺថា ជាបញ្ជីឯកសារសំណុំរឿងដែលមានលក្ខណៈភ្ជាប់កាតព្វកិច្ច ដែលភាគីនានាអាចប្រើប្រាស់នៅពេលសវនាការនោះទេ។

១៩. ការបកស្រាយខាងលើនេះ គឺមានលក្ខណៈត្រូវគ្នាទាំងស្រុងទៅនឹងសេចក្តីប្រកាសពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការអនុវត្តវិធាន៨៧(៤)។ នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះបានញែកចេញឲ្យឃើញច្បាស់ពីភាពខុសគ្នាមួយរវាង៖ ក) ភស្តុតាងដែលមាននៅក្នុងសំណុំរឿង (រួមទាំង ភស្តុតាងដែលភាគីបានស្នើនៅក្នុងបញ្ជីរបស់ខ្លួន ស្របតាមវិធាន៨០), និង ខ) ភស្តុតាងដែលគេបានស្នើនៅលើកទីមួយ ក្រោយពេលការចាប់ផ្តើមជំនុំជម្រះ។ អង្គជំនុំជម្រះ បានសម្រេចថា វិធាន៨៧(៤) អនុវត្តបានចំពោះតែប្រភេទចុងក្រោយនេះ ប៉ុណ្ណោះ៖

> *នៅក្នុងស្ថានភាពមួយចំនួន <u>សម្ភារៈ/ឯកសារ ដែលមិនស្ថិតនៅក្នុសំណុំរឿងដែលត្រូវបានបញ្ជូនតាំងពីដំបូងមកអង្គជំនុំជម្រះសាលាដំបូង ក៏អាចដាក់ក្នុងសំណុំរឿងដែរ និងអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបានដែរ</u> ទាំងដោយការផ្តួចផ្តើមរបស់អង្គជំនុំជម្រះខ្លួនឯង ឬតាមសំណើពីភាគីណាមួយ។ ឧទាហរណ៍ <u>មុនពេលចាប់ផ្តើមសវនាការ ភាគីអាចបញ្ចូលឯកសារ "ថ្មី" ទៅក្នុងបញ្ជីឯកសាររបស់ខ្លួនបាន</u> (មានន័យថា ឯកសារទាំងឡាយដែលមិនទាន់ស្ថិតក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង) អនុលោមតាមវិធាន៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង។ <u>នៅពេលសវនាការចាប់ផ្តើម ភាគីក៏អាចស្នើសុំដាក់ភស្តុតាងថ្មីបានដែរ (មានន័យថា ភស្តុតាងដែលមិនទាន់មាននៅមុនពេលចាប់ផ្តើមសវនាការ) តាមរយៈសារណាដែលមានសម្អាងហេតុត្រឹមត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង</u>[29]។*

២០. នៅក្នុងសេចក្តីសម្រេចដាច់ដោយឡែកមួយផ្សេងទៀត នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះបានសម្រេចស្រដៀងគ្នានេះដែរថា៖

[29] **E190** សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ៣០ មេសា ២០១២, កថាខណ្ឌទី ១៧។

*ភស្តុតាងទាំងអស់ដែលពីមុនមិនមាននៅក្នុងសំណុំរឿង និង/ឬ មិនមាននៅក្នុងបញ្ជីរបស់ភាគី ស្របតាមវិធាន៨០(៣) នៃវិធានផ្ទៃក្នុង គឺជាភស្តុតាងថ្មីដែលត្រូវគោរពតាមលក្ខខណ្ឌនៃភាពអាចទទួលយកបានដ៏តឹងរ៉ឹងនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ តាមរយៈសារណាដោយមានសម្អាងហេតុ ភាគីត្រូវបង្ហាញថា ភស្តុតាងថ្មីទាំងនេះពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ និង/ឬ មិនអាចរកឃើញ និងពុំត្រូវបានផ្តល់ឱ្យនៅពេលមុន ទោះបីជាបានខិតខំយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវរួចហើយក៏ដោយ។ ភស្តុតាងថ្មីក៏ត្រូវតែអាចនាំដល់ការលាតត្រដាងការពិត និងត្រូវបំពេញលក្ខខណ្ឌនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងផងដែរ*[30]។

២១. ការបកស្រាយនេះ មិនគ្រាន់តែសមហេតុសមផលប៉ុណ្ណោះទេ ថែមទាំងស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌ទៀតផង។ វាអនុញ្ញាតឱ្យមានការទទួលយកនូវភស្តុតាងពាក់ព័ន្ធដែលអាចរកបាន និងដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ខណៈដែលវាបានធានាថាគ្រប់ភាគីទាំងអស់ មានការជូនដំណឹងគ្រប់គ្រាន់ស្តីពីភស្តុតាងបែបដូច្នោះ ដើម្បីធ្វើការត្រៀមរៀបចំសម្រាប់សវនាការ។ គ្រប់ភាគីទាំងអស់អាចចូលមើលឯកសារនានា ដែលសហចៅក្រមស៊ើបអង្កេត បានដាក់ចូលទៅក្នុងសំណុំរឿង តាំងពីច្រើនឆ្នាំមកហើយ។ ដោយស្ថិតនៅក្រោមការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) និងលក្ខខណ្ឌតម្រូវទូទៅនៃការជូនដំណឹងសមហេតុសមផល គឺមិនមានភាគីណាមួយត្រូវបានគេប៉ះពាល់ដោយការទទួលយកភស្តុតាងបែបដូច្នោះនោះឡើយ។ លើសពីនេះ អង្គហេតុពិតដែលថាមិនមានភាគីណាមួយត្រូវបានប៉ះពាល់ដោយការបកស្រាយវិធាន៨៧(៤)បែបដូច្នេះ គឺត្រូវបានបង្ហាញដោយអង្គហេតុពិតដែលថាគ្រប់ភាគី ទាំងអស់បានចូលរួមនៅក្នុងញត្តិ ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនេះ។

២២. ចំពោះមូលហេតុដូចបានថែងនៅខាងលើនេះ ភាគីនានាសូមស្នើដោយគោរព ដល់អង្គជំនុំជម្រះសាលាដំបូង៖

ក. សូមពិចារណា*ឡើងវិញ* អំពីការអនុវត្តវិធាន៨៧(៤) នៅក្នុងសំណុំរឿង០០២/០២ និងដោយតាមលទ្ធផលចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល សូមឱ្យធ្វើការសម្រេចថា វិធាននេះនឹងត្រូវអនុវត្តចំពោះឯកសារ/សម្ភារៈដែលត្រូវបានស្នើសុំ ឱ្យ

[30] **E299** សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយក កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ១៥ សីហា ២០១៣, កថាខណ្ឌទី២២។

ទទួលយក នៅក្រោយសវនាការបឋមបន្ថែម នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ តែប៉ុណ្ណោះ, និង

ខ. សូមឱ្យធ្វើការបញ្ជាក់ថា ពាក្យ "ភស្តុតាងថ្មី" នៅក្នុងវិធាន៨៧(៤) គឺយោងសំដៅដល់ភស្តុតាងណាដែលមិនមាននៅក្នុងសំណុំរឿង ឬមិនមាននៅក្នុងបញ្ជីរបស់ភាគី ស្របតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ។

| **ឈ្មោះ** | **ហត្ថលេខា** | **កាលបរិច្ឆេទ** |
|---|---|---|
| លោកស្រី **ជា លាង**<br>សហព្រះរាជអាជ្ញា | [signature] | ១៥ សីហា ២០១៤ |
| លោក **Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | [signature] | ១៥ សីហា ២០១៤ |
| លោក **ពេជ អង្គ**<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | [signature] | 15/08/2014 |
| លោកស្រី **Marie GUIRAUD**<br>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | [signature] | 15/08/2014 |